# សេចក្តីជូនដំណឹង

## ស្តីពី

## ការទទួលបានការអនុញ្ញាតឱ្យ ធនាគារ អេស៊ីលីដា ភីអិលស៊ី ប្រកបអាជីវកម្មបេឡងកាស្សូរេន ជាម៉ូឌែលភ្នាក់ងារ ក្រុមហ៊ុនព្រូដិនសល និងក្រុមហ៊ុនហ្វូតតេ

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (“**ធនាគារ អេស៊ីលីដា**”) ជាធនាគារពាណិជ្ជទីមួយនៅកម្ពុជា ដែលបានបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈនៅកម្ពុជា មានកិត្តិយស សូមជម្រាបជូនដំណឹងដល់សាធារណជន មេត្តាជ្រាបថា ធនាគារ អេស៊ីលីដា បានទទួលអាជ្ញាបណ្ណ និងការអនុញ្ញាត ពីធនាគារជាតិ នៃ កម្ពុជា និងនិយ័តករធានារ៉ាប់រងកម្ពុជាឱ្យធនាគារ អេស៊ីលីដា ប្រកបអាជីវកម្មបេឡងកាស្សូរេនជាម៉ូឌែលភ្នាក់ងាររបស់ក្រុមហ៊ុនព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អឹស្សូរ៉ិនស៍ ម.ក (“**ក្រុមហ៊ុនព្រូដិនសល**”) និងក្រុមហ៊ុនហ្វូតតេ អ៊ិនស្សូរ៉ឹនស៍ (ខេមបូឌា) (“**ក្រុមហ៊ុនហ្វូតតេ**”)។

តាមរយៈអាជ្ញាបណ្ណ និងការអនុញ្ញាតខាងលើ **ធនាគារ អេស៊ីលីដា** ជាអ្នកតំណាងឱ្យ **ក្រុមហ៊ុនព្រូដិនសល** និង**ក្រុមហ៊ុនហ្វូតតេ** ផ្សព្វផ្សាយ និងលក់ផលិតផល និងសេវាកម្មធានារ៉ាប់រងអាយុជីវិត និងទូទៅ ជូនដល់អតិថិជននៅតាមបណ្តាការិយាល័យ ធនាគារ អេស៊ីលីដា។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ១១រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**

ធនាគារ អេស៊ីលីដា ភីអិលស៊ី
ACLEDA BANK PLC.

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងដូចខាងក្រោម៖
- ទូរស័ព្ទ ៖ +៨៥៥ (០)១៥ ៩០០ ៣៣៣ / +៨៥៥ (០)១២ ៦៧៣ ៣០៩
- អ៊ីម៉ែល ៖ veourn.keosath@acledabank.com.kh